# មន្ទានុភាព ?

តើលោក សម រង្ស៊ី គាត់មាន មន្ទានុភាព នៅចំពោះមុខ អំណាចអាវុធរបស់ ហ៊ុន សែន ដែរឬទេ ? យោងតាមការរៀបចំទុកជាមុន មានទំហំ ជាផែនការ នៃយុទ្ធសាស្ត្រសង្គ្រាម ដើម្បីចាប់បុគ្គល រង្ស៊ី វាអាចសន្និដ្ឋានបានថាប្រហែលជា គេទុក នរៈនេះ ជាមនុស្សអស្ចារ្យ មានមន្ទានុភាព អាចប្រយុទ្ធយកឈ្នះកងទ័ពបក្សនៅភ្នំពេញបាន។ ដោយតក្ក របបផ្តាច់ការ ត្រូវតែមានវិធានការបង្ការដូច្នេះឯង ព្រោះគេដឹកច្បាស់ថា គេគ្មានការគាំទ្រ ពីសំណាក់ប្រជាពលរដ្ឋនោះឡើយ ហើយកត្តា នៃប្រជាជននេះឯង វាអាចជាមន្ទានុភាពរបស់បុគ្គល រង្ស៊ី។ តែ នរៈនេះធ្លាប់ក្រវែងចោល ប្រជាអំណាចនៅឆ្នាំ ២០១៤ ដើម្បីសម្រុះសម្រួលជាមួយ ហ៊ុន សែន។ លើកនេះ រង្ស៊ី គាត់អំពាវនាវដ៏ស្វាហាប់ ឲខ្មែរងើបបះបោរ ដើម្បីរំលំបុគ្គល ហ៊ុន សែន ចាប់ពីថ្ងៃទី៩ វិច្ឆិកា ដែលជាថ្ងៃ ដែលគាត់សន្មត់ថាជាទិវា នៃមាតុភូមិនិវត្តន៍របស់គាត់។ សួរថា តើប្រជាពលរដ្ឋខ្មែរនៅមានការទុកចិត្តលើបុគ្គល រង្ស៊ី ទៀតដែរឬទេ ? ប៉ុន្តែ ប្រជាប្រតិកម្មជាអ្វីដែលមិនទាន់ដឹង សំរាប់ សែន និង រង្ស៊ី ផង ដែលវានាំបង្កើតឲមានជាល្បែងភ្នាល់គ្នា, ក្នុងល្បែងនេះ រង្ស៊ី នឹកភ្នកលើកម្លាំងប្រជាពលរដ្ឋ ដែលអាចទុកជា មន្ទានុភាព រីឯ សែន វិញយកកម្លាំងអាវុធ ជាទុន នៅក្នុងតក្ក ទុក រង្ស៊ី ជាសត្រូវ។ សួរថាតើប្រជាពលរដ្ឋខ្មែរ ជា ឧបករណ៍ ឬ មន្ទានុភាព ក្នុងល្បែងនេះ ទំរាំ យួនយកស្រុកទាំងមូល ?